FARMER NOTES

ព្រឹត្តិបត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ការធ្វើជីកំប៉ុស្តិ៍

ជីលាមកសត្វ ផេះ ចំបើង ស្មៅ និងស្លឹករុក្ខជាតិ គឺជាសារធាតុចិញ្ចឹមដែលត្រូវការចាំបាច់ណាស់សម្រាប់ដំណាំ។ ជីទាំងនោះជាជីសរីរាង្គ ដើម្បីឲ្យជីងាយរលាយ និងផ្តល់នូវសារធាតុចិញ្ចឹមសម្រាប់ដំណាំ យើងត្រូវធ្វើជាជីកំប៉ុស្តិ៍។

## ១. សារៈសំខាន់នៃការប្រើជីកំប៉ុស្តិ៍

- ជួយកែលម្អជីជាតិ និងផលិតភាពដី
- ជួយឲ្យដីធូរ ងាយស្រួលដល់ការលូតលាស់របស់ដំណាំ និងខ្យល់ចេញចូលក្នុងដីបានល្អ
- ជួយដីក្នុងការចាប់យកទឹក និងជីជាតិ
- បង្កើនសត្វមានជីវិតរស់នៅក្នុងដី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ។
- ជួយជំរុញឲ្យជីគីមី មានប្រសិទ្ធភាពនៅពេលប្រើលាយជាមួយជីកំប៉ុស្តិ៍
- បន្ថយជាតិពុលនៃដី

## ២. កត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្តិ៍

**ជោគជ័យ**នៃការធ្វើជីកំប៉ុស្ត គឺការកើនឡើងនូវចំនួនសារធាតុចិញ្ចឹមនៅក្នុងដី ដែលសារធាតុទាំងនេះធ្វើឲ្យដំណាំលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់។ មានកត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្តិ៍គឺះ

- ធាតុផ្សំសម្រាប់ធ្វើជីកំប៉ុស្តិ៍ ដូចជាលាមកសត្វ ដើមពោត ចំបើង ស្មៅ ស្លឹកឈើ និងផេះ
- ខ្យល់នៅក្នុងគំនរជីកំប៉ុស្តិ៍សមស្រប
- សំណើមនៃគំនរជីសមល្មម មិនជោគពេក ហើយក៏មិនស្ងួតពេកដែរ
- សីតុណ្ហភាព



**សារ**ធាតុចិញ្ចឹមនៃជីលាមកសត្វ កាកសំណល់រុក្ខជាតិ ក្នុងនោះរាប់បញ្ចូលទាំងកាកសំណល់ពពួកសណ្តែក និងលាមកសត្វពាហនៈនៅក្នុងសារធាតុ ទាំងនោះមានបរិមាណសារធាតុចិញ្ចឹមច្រើនដែលត្រូវការដោយដំណាំ។ គួរចៀសវាងប្រើវត្ថុដែលមានសសៃៗ និងកំទេចឈើ ដូចជាដើមព្រលិត ដើមរុក្ខជាតិតូចៗដែលគេច្រើនដាំលម្អផ្ទះ ព្រោះរុក្ខជាតិទាំងនេះវាមិនងាយនឹងរលួយ ឡើយ។

ការដាក់ឲ្យត្រូវខ្យល់ ឬការធ្វើឲ្យមានខ្យល់ចេញចូលក្នុងគំនរជី គឺជាការចាំបាច់ក្នុងការធ្វើឲ្យជីឆាប់ផុយរលួយ

គំនរជីគ្មានខ្យល់ចេញចូលនាំឲ្យជីបង្កើតជាឧស្ម័នពុល និងអាស៊ីតសរីរាង្គដែលផ្តល់ឥទ្ធិពលអាក្រក់ដល់ដំណាំ ។

**គំនរ**ជីកំប៉ុស្តិ៍ត្រូវតែមានបរិមាណសំណើមសមស្រប គំនរជីដែលមានសភាពសើមពេកនាំឲ្យជីហាប់ និងស្អិត តែបើគំនរជីនោះស្ងួតពេកក៏នាំឲ្យជីមិនងាយផុយរលួយដែរ។ សីតុណ្ហភាពសមស្រប គឺជាសារៈប្រយោជន៍មួយដែរ ក្នុងការធ្វើជីកំប៉ុស្តិ៍។ កាលណាគំនរជីមានសីតុណ្ហភាពខ្ពស់ នាំឲ្យជីឆាប់ផុយរលួយល្អ ហេតុនេះវាជាការចាំបាច់ណាស់ដែរ ត្រូវរក្សាសីតុណ្ហភាពនៃគំនរជី។ ជាទូទៅកម្តៅនៃគំនរជីត្រូវកើនឡើងក្នុងអំឡុងពេលពី ១ ទៅ ២ថ្ងៃ កាលណាផ្នែកខាងក្នុងនៃគំនរជីមានកម្តៅ បានន័យថាភាពរលួយនៃជីកំប៉ុស្តិ៍កំពុងដំណើរការ។







### ៣. របៀបធ្វើជីកំប៉ុស្ត

**ដំបូង**ត្រូវប្រមូលវត្ថុធាតុដើមជីកំប៉ុស្តិ៍ អ្នកអាចប្រើលាមកសត្វពាហនៈ ដើមពោត ចំបើង ស្មៅ និងស្លឹកឈើ។ ត្រូវយកចេញវត្ថុណាដែលយើងដឹងថាមិនរលួយ ដូចជាសំបកកំប៉ុង ប្លាស្ទិច អំបែងកែវ ជាដើម។

កាប់ចិញ្ច្រាំចំបើង និងស្មៅ ដើម្បីឲ្យចរន្តខ្យល់ចេញចូលបានល្អ និងងាយរលួយ។ ត្រូវជ្រើសកន្លែងមានម្លប់ហើយទួលបន្តិចមិនដក់ទឹក និងគួរនៅជិតប្រភពទឹកផងនោះ ជាកន្លែងសមស្របសម្រាប់គំនរជីកំប៉ុស្តិ៍របស់អ្នក។




ដោតបន្ទះឫស្សីចំណាំកន្លែងលើផ្ទៃដីមានទំហំ ២ ម X ៦ ម សម្អាតផ្លាក្បែរនោះឲ្យមានទំហំប៉ុនគ្នា ព្រោះអ្នកប្រើផ្លានោះចូកត្រលប់ជីកំប៉ុស្តិ៍របស់អ្នក។ គរគំនរសំណល់រុក្ខជាតិឲ្យបានកម្ពស់ ១៥ ស.ម កៀរាស់គំនរតែមិនត្រូវសង្កត់ ឬជាន់វាឡើយ។ គំនរនេះមិនត្រូវឲ្យហាប់ពេកទេ កម្ពស់ ៥ សង់ទីម៉ែត្រ ពីលើគំនរសំណល់រុក្ខជាតិ បន្ទាប់មកត្រូវចាក់ផេះ ឬកំបោរកម្រាស់ ២ សង់ទីម៉ែត្រ លើលាមកសត្វ អ្នកអាចដាក់បន្ថែមជីអ៊ុយរ៉េ ចំនួន ១ គីឡូក្រាម ឬអាម៉ូញ៉ូមស៊ុលផាត ឬក៏ស៊ុបពែផូស្វាត បន្តការរៀបគំនរដោយដាក់កាកសំណល់រុក្ខជាតិ លាមកសត្វ និងផេះ រហូតដល់គំនរនេះកម្ពស់បានពី ១ ម៉ែត្រទៅ ១,៥ ម៉ែត្រ។ ដើម្បីរក្សាសំណើម ត្រូវស្រោចទឹកលើគំនរនោះដោយប្រើធុងស្រោចដំណាំ។ ត្រូវស្រោចទឹកក្នុងកម្រិតមធ្យមធ្វើដូច្នេះទើបទឹកមិនហៀរពីគំនរ។

ចូកត្រលប់កំប៉ុស្តិ៍ក្រោយរយៈពេល ៣ សប្តាហ៍ យកផ្នែកលើទៅក្រោម និងផ្នែកក្រោមទៅលើ ធ្វើដូច្នេះដើម្បីឲ្យខ្យល់ចូលបានល្អ និងអាចបង្កើតឲ្យជីឆាប់រលួយ។ ស្រោចទឹកបន្ថែមដើម្បីរក្សាគំនរជីឲ្យមានសំណើម។ ៥ សប្តាហ៍ ក្រោយមកត្រូវចូកជីដាក់កន្លែងដើមវិញ ដើម្បីឲ្យកាន់តែប្រសើរត្រូវគ្របគំនរជី ដោយប្រើក្រណាត់ប្លាស្ទិក ឬក៏សម្បុកបារ ត្រូវគ្របគំនរជីឲ្យ





ជិតលើកលែងតែផ្នែកខាងក្រោមនៃគំនរជី ដើម្បីរក្សាកម្ដៅ និងបន្ថយនូវរំហួតទឹក។ ទុកគំនរជីឲ្យរលួយក្នុងរយៈពេល ៤ សប្ដាហ៍ នៅពេលជីអាចប្រើការបាន ជាទូទៅវាមានពណ៌ត្នោតចាស់ក្រមៅ ហើយមានសភាពដូចដី នៅពេលនេះ អ្នកអាចប្រើជីកំប៉ុស្ដដូចជាជីសរីរាង្គ៕